**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គ.ជ.អ.ប
NCDD

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

ថ្ងៃអង្គារ ១០កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
# វេទិកាថ្នាក់ជាតិ
# ស្តីពីការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍ
# តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់សាធារណជន និងបណ្តាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប សហការជាមួយអង្គការសង្គមស៊ីវិលនឹងរៀបចំវេទិកាថ្នាក់ជាតិ ស្តីពី "**ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**" នៅថ្ងៃទី២៣-២៤ ខែសីហា ឆ្នាំ២០១៨ ចាប់ពីម៉ោង ៨:០០ព្រឹក នៅសណ្ឋាគារហ៊ីម៉ាវ៉ារី (Himawari Hotel) ។

វេទិកាថ្នាក់ជាតិនេះនឹងប្រារព្ធពិធីបើកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ឌី ច័ន្ទផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (គ.គ.អ.ស)**។

វេទិកាថ្នាក់ជាតិនេះមានគោលបំណងដើម្បីប្រមូលចងក្រងមេរៀន បទពិសោធន៍ល្អៗ បញ្ហាប្រឈម និងរៀបចំផែនការកែលម្អក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ដែលមានការចូលរួមពីសមាជិក គ.គ.អ.ស (ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប អភិបាលរងខេត្តជាប្រធានមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរដ្ឋបាលខេត្តគោលដៅ មន្ទីរសុខាភិបាល មន្ទីរអប់រំ យុវជន និងកីឡា មន្ត្រីបង្គោលគណនេយ្យភាពសង្គមខេត្ត ស្រុក ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ អង្គភាពផ្តល់សេវាទាំងបី (រដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព) ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអ្នកពាក់ព័ន្ធប្រមាណជា ២០០នាក់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមអញ្ជើញអ្នកសារព័ត៌មានទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។៤

*សូមទាក់ទងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមុនតាមរយៈ:*
*លេខទូរស័ព្ទ 017699987 / 077 785 445 Email: vansophorn@ncdd.gov.kh*
*Website: www.ncdd.gov.kh Facebook Page: www.facebook.com/ncdds/*